**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

**Committee for Free and Fair Elections in Cambodia**

ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១១

# <u>សេចក្តីប្រកាសព័ត៌មាន</u>

# <u>ស្តីពី</u>

## <u>លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ឃុំកោះស្រឡាយ  ស្រុកសៀមបូក ខេត្តស្ទឹងត្រែង</u>

គណៈកម្មាធិការខុមហ្វ្រែល បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយស្តីពី **ការកំណត់តម្រូវការជាអាទិភាព ក្នុងឃុំ សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ **ឃុំកោះស្រឡាយ** ស្រុកសៀមបូក **ខេត្តស្ទឹងត្រែង** កាលពីថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១១។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ ៥០ នាក់ (៣២% ជាស្ត្រី) មកពីគ្រប់ភូមិក្នុងឃុំ ដែលរួមមានតំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ និងជាសមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង ៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្ន យកចិត្តទុកដាក់ដោះស្រាយ និង/ឬគណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

| **តម្រូវការជាអាទិភាព ទាំង ៥ ក្នុង ឃុំកោះស្រឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង** |
|---|
| **១ - ការសាងសង់ផ្លូវ**<br>- សុំផ្លូវលំក្រាលគ្រួសក្រហមកាត់បណ្តោយកោះឆ្លងកាត់ទាំង ៤ ភូមិ **គឺភូមិស្វាយ ភូមិកាំងដែក ភូមិស្នាកោះ** និង**ភូមិភ្នល់** ដែលមានទទឹងផ្លូវ ៨ម៉ែត្រ និងចំងាយ ១៤គីឡូម៉ែត្រ ដោយដាក់លូកាត់ផ្លូវ ចំនួន ៣០ កន្លែង ហើយមួយកន្លែងត្រូវប្រើប្រាស់ លូមុខកាត់ ១ ម៉ែត្រ ចំនួន ៩ កង់ ដោយចាប់ផ្តើមអនុវត្តពីឆ្នាំ២០១២ បញ្ចប់នៅឆ្នាំ២០១៥។ |
| **២ - ការសាងសង់ស្ពាន**<br>- សុំសាងសង់ស្ពាន៥កន្លែង នៅ**ភូមិស្វាយ** ៣កន្លែង ប្រវែង ៤៥ ម៉ែត្រ ២៥ ម៉ែត្រ ២៥ ម៉ែត្រ **ភូមិកាំងដែក** ប្រវែង ៤៥ម៉ែត្រ និងនៅ**ភូមិភ្នល់** ១កន្លែង ប្រវែង៣៥ម៉ែត្រ ដោយចាប់ផ្តើម អនុវត្តពីឆ្នាំ |

<u>ទីស្នាក់ការកណ្តាល</u> ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

<u>Central Office</u> : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Phone : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៣ - ការសាងសង់មណ្ឌលសុខភាព**

- សុំមណ្ឌលសុខភាព ១ ខ្នង មាន ៥បន្ទប់នៅ**ភូមិកាំងដែក** ដំបូលប្រក់ក្បឿង ព្រមទាំងមានបុគ្គលិកពេទ្យចំនួន ៦នាក់ដែលមានជំនាញ ជម្ងឺកុមារ ២នាក់ ពេទ្យឆ្មប ២នាក់ និងជម្ងឺទូទៅ ២នាក់ ហើយមានបំពាក់សំភារៈបរិក្ខាពេទ្យ ត្រូវចាប់ផ្តើមអនុវត្តពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៥។

**៤ - ម៉ាស៊ីនភ្លើង**

- សុំម៉ាស៊ីនភ្លើងចំនួន ៤គ្រឿងសម្រាប់ ៤ភូមិ ដោយមួយគ្រឿងមានកម្លាំងម៉ាស៊ីនដែលអាចអូសឌីណាម៉ូភ្លើង ១៥ គីឡូវ៉ាត់ និងភ្ជាប់បណ្តាញចូលតាមគ្រួសារដោយផ្តើមអនុវត្តពីដើមឆ្នាំ២០១២ និងបញ្ចប់ នៅចុងឆ្នាំ២០១៣។

**៥ - អាងស្តុកទឹក**

- សុំអាងស្តុកទឹកចំនួន ៤០០ សំរាប់ ៤០០គ្រួសារ ដោយអាងនិមួយៗ ប្រើប្រាស់លូ ៤ កង់ ចាប់ផ្តើមអនុវត្តពីខែកុម្ភៈ ដល់ចុងឆ្នាំ ២០១២។

មុនពេលបញ្ចប់សិក្ខាសាលា មានកម្មវិធីប្រគល់របាយការណ៍ ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។ លោកស្រី **ជា ណម** ប្រធានក្រុមប្រឹក្សា**ឃុំកោះស្រឡាយ** និងជាតំណាងគណបក្សប្រជាជនប្រចាំឃុំ មានប្រសាសន៍ថា "សិក្ខាសាលាថ្ងៃនេះមានសារៈសំខាន់ណាស់ ប្រជាពលរដ្ឋបានជជែក និងលើកតម្រូវការរបស់ខ្លួន និងបានដឹងពីផែនការរបស់ឃុំ។ លោកស្រីបន្តថា តម្រូវការជាអាទិភាពដែលបានលើកឡើងក្នុងថ្ងៃមួយចំនួនមានក្នុងកម្មវិធីវិនិយោគឃុំរួចហើយ។ ចំពោះតម្រូវការអាទិភាពណាដែលថ្មី នឹងដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍឃុំខាងមុខទៀត និងយកគម្រោងទៅពពាយលក់បន្តទៀត ក្រែងមានការចាប់អារម្មណ៍ពីដៃគូអភិវឌ្ឍន៍ ឬពីមន្ទីរវិស័យនានា ។

សិក្ខាសាលានេះ មានគោលបំណង ឱ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបានៈ

១. ការយល់ដឹងអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ ដាច់ស្រយាល នឹងត្រូវបានចងក្រងជា របាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន ជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

១-លោក **ម្លូច ឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៩៧១ ៣២៦**

២-អ្នកស្រី **ហេង សុគន្ធា** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦៩**

[1] No 018